**សុន្ទរកថាស្វាគមន៍**

**សិក្ខាសាលាផ្សព្វផ្សាយលទ្ធផល** COP 20 **នៃ** UNFCC

**ឯកឧត្តម ទី សុគន្ធ រដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ**

សណ្ឋាគារសាន់វេ, រាជធានីភ្នំពេញថ្ងៃទី០៣ ខែមីនាឆ្នាំ២០១៥

- **សូមគោរពឯកឧត្តមបណ្ឌិតសាយសំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ**
- **ឯកឧត្តម Jean-Claude Poimboeuf ឯកអគ្គរដ្ឋទូតនៃសាធារណៈរដ្ឋបារាំងប្រចាំនៅកម្ពុជា**
- **ឯកឧត្តមលោកជំទាវសមាជិកសមាជិកានៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុនិង ថ្នាក់ដឹកនាំក្រសួងបរិស្ថាន**
- **ឯ.ឧ. ល.ជ លោក លោកស្រី អ្នកនាងកញ្ញា សមាជិក សមាជិកាអង្គសិក្ខាសាលា ជាទីគោរពរាប់អាន!**

ថ្ងៃនេះក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំពិតជាមានកិត្តិយសនិងសេចក្តីសោមនស្សរីករាយបំផុត ដែលបានចូលរួមក្នុង"**សិក្ខាសាលាផ្សព្វផ្សាយលទ្ធផលសន្និសីទភាគីលើកទី២០នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ**នាឱកាសនេះ។ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅនិងថ្លែងអំណរគុណជាទីបំផុតចំពោះឯកឧត្តមលោកជំទាវ លោក លោកស្រីអ្នកនាងកញ្ញាទាំងអស់ ដែលបានចំណាយពេលវេលាដ៏មមាញឹក និង មានតម្លៃបំផុត អញ្ជើញមកចូលរួមនៅក្នុងសិក្ខាសាលាដ៏មានសារសំខាន់ជាសាកលនេះ។ នេះ គឺជាសក្ខីកម្មមួយបង្ហាញពីការយកចិត្តទុកដាក់និង ការប្តេជ្ញាខ្ពស់បំផុតរបស់យើងទាំងអស់គ្នាចំពោះការចូលរួមស្វែងរកដំណោះស្រាយបញ្ហាប្រឈមជាសាកលនៃការប្រែប្រួលអាកាសធាតុរបស់សហគមន៍ពិភពលោកទាំងមូល ដើម្បីធានាដល់អនាគតភពផែនដីមួយ ដែលគ្មានភាពក្រីក្រនិងមានការអភិវឌ្ឍន៍ដោយចីរភាពពិតប្រាកដសម្រាប់ទាំងអស់គ្នា។

ការប្រែប្រួលអាកាសធាតុត្រូវបានទទួលស្គាល់ជាសាកលកាន់តែខ្លាំងឡើងជាលំដាប់ថាជាវិបត្តិដ៏ធំបំផុតមួយរបស់ពិភពលោក ដែលត្រូវបាននិងកំពុងបន្តបង្កឡើង ដោយសារសកម្មភាពរបស់មនុស្សខ្លួនឯងតាមរយៈការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅក្នុងបរិយាកាសកាន់តែច្រើនឡើងនោះ ហើយបើគិតពីពេលចាប់ផ្តើមដំណើរការបដិវត្តឧស្សាហកម្មមកដល់បច្ចុប្បន្ននេះ កំហាប់នៃឧស្ម័នផ្ទះកញ្ចក់មានការកើនឡើងជាង៤០% ជាពិសេសដោយសារការប្រើប្រាស់ឥន្ធនៈផូស៊ីលនិងការផ្លាស់ប្តូរការប្រើប្រាស់ដី។ យើងម្នាក់ៗក៏ដូចពិភពលោកទាំងមូលបានមើលឃើញយ៉ាងច្បាស់ និង ឆ្លងកាត់បទពិសោធន៍ជាក់ស្តែងកាន់តែច្រើនឡើងពីឥទ្ធិពលអាក្រក់នៃការប្រែប្រួលអាកាសធាតុ តាមរយៈគ្រោះមហន្តរាយធម្មជាតិជាបាតុភូតមិនប្រក្រតី ដូចជា គ្រោះរាំងស្ងួត រលកកម្តៅ ទឹកជំនន់ ខ្យល់ព្យុះ... ដែលកាន់តែញឹកញាប់ឡើង និង ខ្លាំងក្លាឡើង ហើយបានបំផ្លិចបំផ្លាញដល់អាយុជីវិតទ្រព្យសម្បត្តិនិងការអភិវឌ្ឍនៅលើភពផែនដីយើងនេះជាបន្តបន្ទាប់ ទាំងក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ កំពុងអភិវឌ្ឍនិងប្រទេសអភិវឌ្ឍតិចតួច ។ ការប្រែប្រួលអាកាសធាតុបាននិងកំពុងក្លាយជាឧបសគ្គដ៏ចម្បងមួយសម្រាប់ការសម្រេចបានតាមគោលដៅនៃការអភិវឌ្ឍន៍ដោយចីរភាព ការលុបបំបាត់ភាពក្រីក្រនិងការធានាបាននូវសន្តិសុខស្បៀង និង អាហារូបត្ថម្ភ សម្រាប់ចិញ្ចឹមមនុស្សជាង៩ពាន់លាននាក់ក្នុងឆ្នាំ២០៥០ខាងមុខនេះ។ការប្រែ

ប្រែប្រួលអាកាសធាតុនឹងធ្វើឱ្យផលិតកម្មកសិកម្ម ដែលជាប្រភពផ្គត់ផ្គង់ស្បៀងអាហាររបស់ពិភពលោកមានការថយចុះប្រមាណ២០%ក្នុងឆ្នាំ២០៥០ នៅខណៈដែលពិភពលោកត្រូវការបង្កើនយ៉ាងតិច៥០%បន្ថែមលើសពីកម្រិតផលិតកម្មនាពេលបច្ចុប្បន្ននេះ។ ក្នុងបរិការនេះ វិស័យកសិកម្មបានក្លាយទៅជាស្នូលនៃការអភិវឌ្ឍដែលមានសារសំខាន់ជាយុទ្ធសាស្រ្ត សម្រាប់ការបង្កើតក្របខ័ណ្ឌអភិវឌ្ឍន៍ដោយចីរភាពរបស់ពិភពលោកក្រោយឆ្នាំ២០១៥។ ជាក់ស្តែង វិស័យកសិកម្មគឺជាប្រភពអាចផ្តល់មុខរបរការងារដល់មនុស្សច្រើនបំផុតជាអ្នកនាំឱ្យមានកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន(inclusive) និង មានឥទ្ធិពលកាត់បន្ថយភាពក្រីក្រខ្លាំងបំផុត ហើយក៏ជាវិស័យ ដែលមានតម្រូវការប្រើប្រាស់ធនធានធម្មជាតិ ដូចជា ដីដាំដុះ និង ទឹកស្រោចស្រព(ដល់ជាង៧០%)ច្រើនជាងគេ ហើយមានការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ជាសាកលដ៏ធំមួយ (ដល់ជាង៣០%) តែក៏ជាវិស័យដែលអាចផ្តល់នូវសេវាកម្មប្រព័ន្ធអេកូឡូស៊ីនិងមានសក្តានុពលស្រូបយកការបូនដ៏ធំសំបើមផងដែរ។

"យើងមិនអាចដោះស្រាយបញ្ហារបស់យើងជាមួយការគិតគូរ ដែលបានប្រើប្រាស់សម្រាប់បង្កើតបញ្ហានោះទេ = We cannot solve our problems with the same thinking we used when we created them." នេះគឺជាសំដីរបស់បុរសលេខ១នៃសតវត្សទី២០ Albert Einstein ។ វិស័យកសិកម្មត្រូវតែមានការផ្លាស់ប្តូរគឺផ្លាស់ប្តូរពីការបង្កើនផលិតកម្មដែលតែងតែនាំឱ្យមានការបាត់បង់ធនធានធម្មជាតិជីវៈចម្រុះ ឱនភាពដីធ្លីនិងការបញ្ចេញកាបូនដ៏ច្រើននោះ ទៅជាប្រព័ន្ធកសិកម្មមួយ ដែលអាចបង្កើនផលិតភាពនិងចំណូលជាប្រចាំ មានសមត្ថភាពធន់ទ្រាំខ្ពស់ជាមួយការប្រែប្រួលអាកាសធាតុនិងមានការបញ្ចេញកាបូនទាប។ ដូច្នេះ យើងត្រូវតែចាត់វិធានការនិងសកម្មភាពជាក់ស្តែងនានា ដើម្បីតម្រង់ទិសពីភាពកាន់តែមិនប្រាកដប្រជានេះឆ្ពោះទៅក្នុងលំហប្រតិបត្តិការមួយមានសុវត្ថិភាព ដោយមិនចាំបាច់ឆ្លងកាត់មាត់ទ្វារគ្រោះថ្នាក់នៃបរិស្ថាន។ក្នុងការខិតខំប្រឹងប្រែង ដើម្បីបន្សាំនិងកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងធានាបាននូវសន្តិសុខស្បៀងនោះ ជាចាំបាច់ត្រូវការនូវវិធានការអន្តរាគមន៍ដ៏សំខាន់មួយចំនួន ដើម្បីផ្លាស់ប្តូររបៀបនិងការអនុវត្តក្នុងផលិតកម្ម ការផ្គត់ផ្គង់ ចែកចាយនិងការប្រើប្រាស់ស្បៀងអាហារនាពេលបច្ចុប្បន្ននេះ ពោលគឺយើងត្រូវការធ្វើការវិនិយោគជាយុទ្ធសាស្រ្ត ដើម្បីបង្កើតប្រព័ន្ធផលិតកម្មកសិកម្មធន់នឹងអាកាសធាតុ ធានាការប្រើប្រាស់ដោយប្រសិទ្ធផលនៃធនធាន អភិវឌ្ឍខ្សែសង្វាក់ផ្គត់ផ្គង់មានការបាត់បង់តិច ធានាបាននូវសុវត្ថិភាពអាហារូបត្ថម្ភៈគ្រប់គ្រាន់ និងការលើកទឹកចិត្តដល់ជម្រើសទទួលទានអាហារប្រកបដោយសុខភាព។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ជាទីគោរពរាប់អាន!**

កម្ពុជាត្រូវបានចាត់ថ្នាក់ជាប្រទេសមួយក្នុងចំណោមប្រទេសនៅលើសាកលលោក ដែលងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុ ដោយសារតែជាប្រទេសកសិកម្ម ដែលមានសមត្ថភាពបន្សាំទាប និង ការអភិវឌ្ឍតិចតួច។ វិស័យកសិកម្ម គឺជា មូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចជាតិ និង ជនបទកម្ពុជា ហើយបានធ្វើការអភិវឌ្ឍន៍ផ្លាស់ប្តូរពី**កសិកម្មបែបចិញ្ចឹមឆ្នាំង**ទៅជា**កសិកម្មទំនើប មានពិពិធកម្ម និង ពាណិជ្ជូបនីយកម្មកសិកម្ម**បណ្តើរៗផងដែរ។ ការអភិវឌ្ឍវិស័យនេះផ្តល់ផលប្រយោជន៍ដល់ប្រជាជនកម្ពុជាជាង៨០%ដែលរស់នៅតាមទីជនបទនិងផ្តល់ការងារជាង៥០%នៃកម្លាំងពលកម្មសរុបក្នុងប្រទេស ហើយមានទំហំចូលរួមចំណែកស្មើរតែមួយភាគបីនៃផលិតផលក្នុងស្រុកសរុប។ ប៉ុន្តែ កសិកម្មកម្ពុជានៅគ្របដណ្តប់ដោយការធ្វើកសិកម្មខ្នាតតូច និង ពឹងអាស្រ័យលើទឹកភ្លៀងនៅឡើយ ជាហេតុធ្វើឱ្យវិស័យនេះងាយទទួលរងគ្រោះ ដោយសារឥទ្ធិពលនៃការប្រែប្រួលអាកាស

ជាតុបំផុត។ កំណើនកសិកម្មកម្ពុជាមានប្រែប្រួលឡើងចុះ ស្របទៅតាមភាពអនុគ្រោះ ឬ ភាពឃោរឃៅរបស់អាកាសធាតុ ជាក់ស្តែង កំណើនកសិកម្មមានការថយចុះនៅក្នុងឆ្នាំណាមានភាពរាំងស្ងួតនិងទឹកជំនន់ធ្ងន់ធ្ងរ។ ជាងនេះទៅទៀត បើទោះបីជាកម្ពុជាជាប្រទេសមួយមានការស្រូបយកច្រើនជាងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុបក៏ដោយក៏ប្រភពបញ្ចេញឧស្ម័នផ្ទះកញ្ចក់ធំបំផុតរបស់កម្ពុជា គឺ វិស័យកសិកម្ម និង ផ្នែកដែលពាក់ព័ន្ធជាមួយនឹងវិស័យនេះតែម្តង។ ហេតុនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ បានយកចិត្តទុកដាក់ខ្ពស់បំផុតក្នុងការជម្រុញការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព តាមរយៈការខិតខំព្យាយាមធ្វើការណែនាំអនុវត្តកសិកម្មមានដែលភាពវៃឆ្លាតជាមួយអាកាសធាតុ( Climate Smart Agriculture )ដូចមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពវិស័យកសិកម្មឆ្លើយតបជាមួយការប្រែប្រួលអាកាសធាតុ២០១៤ - ២០១៨ របស់ក្រសួងដែលមានតម្រូវការថវិកាប្រមាណជាង២០០លានដុល្លាអាមេរិក។គោលដៅរួមរបស់វិស័យកសិកម្មគឺការជម្រុញឱ្យមានកំណើនប្រចាំឆ្នាំ៥% (គឺកំណើនផលដំណាំគ្រប់ប្រភេទ១០% ការចិញ្ចឹមសត្វ-៣% និងវារីវប្បកម្ម-១៥%) តាមរយៈការបង្កើនផលិតភាព ពិពិធកម្មនិងពាណិជ្ជូបនីយកម្មកសិកម្ម ជាមួយការយកចិត្តទុកដាក់ខ្ពស់បំផុតដល់ការគ្រប់គ្រងធនធានព្រៃឈើនិងជលផលប្រកបដោយនិរន្តរភាព។ឯកសារផែនការទាំងនេះបានពន្យល់លម្អិតពីបណ្តាជម្រើស"**មិនស្តាយក្រោយ**"សម្រាប់វិស័យកសិកម្មនិងការចិញ្ចឹមជីវិត ហើយក៏បានក្លាយទៅផ្នែកមួយនៃផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុកម្ពុជាឆ្នាំ២០១៤-២០២៣ ដែលបានដឹកនាំសម្របសម្រួលរៀបចំឡើងដោយក្រសួងបរិស្ថានផងដែរ។ ជាប្រទេសអភិវឌ្ឍតិចតួចនិងងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ តែយើងមានសុឆន្ទៈប្តេជ្ញាចិត្តខ្ពស់ធ្វើការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយចីរភាព មិនគ្រាន់តែដើម្បីធានាសន្តិសុខស្បៀង កាត់បន្ថយភាពក្រីក្រ កំណើនសេដ្ឋកិច្ច និង បន្សាំជាមួយការប្រែប្រួលអាកាសធាតុប៉ុណ្ណោះទេ តែក៏ដើម្បីចូលរួមកាត់បន្ថយការប្រែប្រួលអាកាសធាតុជាសាកលផងដែរ។ យើងត្រូវការជំនួយទុនវិនិយោគនិងភាពជាដៃគូអភិវឌ្ឍន៍ពីគ្រប់ភាគីទាំងអស់ដើម្បីសម្រេចបានគោលដៅទាំងនេះ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាជាទីគោរពរាប់អាន**

ដោយផ្អែកលើការអភិវឌ្ឍមានកម្រិតខុសគ្នានៅជុំវិញពិភពលោកនោះ រាល់ការឆ្លើយតបចំពោះបញ្ហាប្រឈមពីការប្រែប្រួលអាកាសធាតុត្រូវឈរលើលើគោលការណ៍ "សមធម៌ និង ការទទួលខុសត្រូវរួម តែក្នុងកម្រិតខុសគ្នាតាមសមត្ថភាព"។នៅកម្ពុជា យើងមានមនសិកាពេញលេញពីតម្រូវការអភិរក្សធនធានរបស់យើងតាមរយៈការប្រើប្រាស់ប្រកបដោយនិរន្តរភាពពិតប្រាកដ។ យើងក៏ជឿជាក់ថា ការប្រើប្រាស់ធនធានដោយប្រសិទ្ធផលត្រូវចាប់ផ្តើមឡើងជាមួយការធានានូវប្រសិទ្ធផលនៃការប្រើប្រាស់ធនធានមនុស្ស ដែលទាមទារនូវការកសាងសមត្ថភាពនិងភាពស្ទាត់ជំនាញជាប្រព័ន្ធ ដែលប្រទេសនិមួយៗអាចធានានូវប្រសិទ្ធផលកាន់តែខ្ពស់ក្នុងរាល់ការខិតខំរបស់មនុស្សម្នាក់ៗ។

អស់រយៈពេលជាងកន្លះសតវត្សរ៍ហើយ ដែលមនុស្សជាតិយើងបានយកចិត្តទុកដាក់ជជែកពិភាក្សាអំពីបញ្ហាប្រែប្រួលអាកាសធាតុ តែយើងនៅតែពុំទាន់មានចំណេះដឹងគ្រប់យ៉ាងពីបញ្ហាប្រែប្រួលអាកាសធាតុនេះនៅឡើយ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ យើងពិតជាមានការយល់ដឹងនិងបទពិសោធន៍គ្រប់គ្រាន់ ដើម្បីធ្វើសេច

ក្តីសម្រេចចិត្ត ចាត់វិធានការសមស្របនិងសកម្មភាពជាក់ស្តែងចំពោះវិបត្តិនៃការប្រែប្រួលអាកាសធាតុដែលបាន និងកំពុងកើតឡើងជាសាកលនេះ បើសិនជាយើងទាំងអស់គ្នាមានការប្តេជ្ញាចិត្តពិតប្រាកដនោះ។ ជាងនេះទៅទៀតជាមួយសមត្ថភាព បទពិសោធន៍ ធនធាន និងបច្ចេកវិទ្យាដ៏សម្បូរបែបរបស់ពិភពលោក រួមនិងការដឹកនាំសម្របសម្រួលប្រកបដោយសមត្ថភាពខ្ពស់និងបទពិសោធន៍ជាច្រើនរបស់សាធារណរដ្ឋបារាំងនោះ យើងមានជំនឿដ៏មុតមាំថា សហគមន៍ពិភពលោកនឹងសម្រេចបាននូវកិច្ចព្រមព្រៀងអាកាសធាតុថ្មីដ៏ល្អប្រសើរមួយនៅក្នុងសន្និសីទភាគីលើកទី២១នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ នាទីក្រុង ប៉ារីស ក្នុងចុងឆ្នាំ២០១៥នេះជាមិនខាន។យើងក៏សង្ឃឹមថា កិច្ចព្រមព្រៀងអាកាសធាតុថ្មីនឹងដោះស្រាយបាននូវភាពប្រឈមគ្រោះថ្នាក់ពីការប្រែប្រួលអាកាសធាតុ ហើយប្រែក្លាយជាឱកាសនិងឧបករណ៍តម្រង់ទិសចេញពីដំណើរការអភិវឌ្ឍដោយគ្មានចីរភាពនាពេលបច្ចុប្បន្ននេះឆ្ពោះទៅដល់ការអភិវឌ្ឍន៍ដោយចីរភាពពិតប្រាកដជាក់ស្តែង។

ខ្ញុំសូមបញ្ចប់សុន្ទរកថាស្វាគមន៍របស់ខ្ញុំដោយសូមរំលឹកឡើងវិញនូវគំនិតគួរឱ្យពិចារណារបស់មហាជីវវិទូ Charles Robert Darwin ដែលមានខ្លឹមសារថា"មិនមែនជាប្រភេទពូជដែលខ្លាំងពូកែបំផុត ឬ វៃឆ្លាតបំផុតនោះទេ ដែលរស់រានមានជីវិត ប៉ុន្តែគឺប្រភេទពូជ ដែលឆ្លើយតបបំផុតជាមួយការប្រែប្រួលនោះ = it is not the strongest of species that survives, nor the most intelligent, but the one most responsive to change."។ ខ្ញុំសូមគោរពជូនពរសិក្ខាសិលាប្រព្រឹត្តទៅប្រកបដោយជោគជ័យមានលទ្ធផលជាផ្លែផ្កាគួរឱ្យពេញចិត្តបំផុត ដែលអាចទៅជាវិភាគទាននិងសកម្មភាពជាក់ស្តែងសម្រាប់ដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុជាសាកលនេះ។ខ្ញុំសូមថ្លែងការកោតសរសើរនិងអំណរគុណដ៏ជ្រាលជ្រៅបំផុតដល់ឯកឧត្តមរដ្ឋមន្ត្រីដៃគូអភិវឌ្ឍន៍ និងថ្នាក់ដឹកនាំនៃក្រសួងបរិស្ថានទាំងអស់ ដែលបានរៀបចំសិក្ខាសាលាដ៏មានសារសំខាន់នេះ និងបានចូលរួមដឹកនាំ អនុវត្តភារៈកិច្ចដោយប្រសិទ្ធភាពនិងជោគជ័យក្នុងការថែរក្សាការពារបរិស្ថាននិងគ្រប់គ្រងការប្រែប្រួលអាកាសធាតុ តាមមាគ៌ានយោបាយដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ត្រឹមត្រូវនិងម៉ឺងម៉ាត់បំផុតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ខ្ញុំក៏សូមគោរពជូនពរបវរមហាប្រសើរចំពោះឯកឧត្តមរដ្ឋមន្ត្រី គណៈអធិបតី ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិនិងសមាជិកសមាជិកានៃអង្គសិក្ខាសាលា សូមជួបប្រទះនូវសេចក្តីសុខចម្រើន និងទទួលបានជ័យជំនះគ្រប់ប្រការតរៀងទៅ។

សូមអរគុណ!